# ធម្មទេសនារបស់លោកឪពុក លី
# អភិបូជាសម្រាប់មរណសាក្សីនៅដីមរណសាក្សី
# តាំងគោក ថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០២០
# យើងបង្កើតផលដែលផ្តល់ការសង្គ្រោះឲ្យមនុស្សលោក

**អត្ថបទទី១៖ កិច្ចការ ១៥,១-៦**

ដំណឹងនេះធ្វើឲ្យបងប្អូនគ្រប់ៗគ្នាមានអំណរសប្បាយយ៉ាងខ្លាំង។ កក ១៥,៣

**ដំណឹងល្អ៖ យ៉ូហាន ១៥,១-៨**

ប្រសិនបើមែកមិនស្ថិតនៅជាប់នឹងដើមទេ វាពុំអាចបង្កើតផលដោយឯកឯងបានឡើយ។ យហ ១៥,៤

លោកអភិបាល និងបងប្អូនជាទីស្រឡាញ់!

ខ្ញុំមានឱកាស ដែលលោកអភិបាលអនុញ្ញាតចែករំលែកអត្ថបទគម្ពីរ ដែលយើងបានស្តាប់នៅថ្ងៃនេះ បុណ្យគោរពព្រះនាងម៉ារីដែលបង្ហាញខ្លួននៅហ្វាទីម៉ា។ ក្នុងអត្ថបទគម្ពីរនេះ ខ្ញុំគិតថាស៊ីនឹងពិធីបុណ្យដែលយើងធ្វើនៅថ្ងៃនេះ ជាពិសេសយើងថ្វាយអភិបូជានៅទឹកដីតាំងគោក ដែលជាទឹកដីមរណសាក្សីរបស់ព្រះសហគមន៍កម្ពុជា។ ព្រះយេស៊ូមានព្រះបន្ទូលថា "**ខ្ញុំហ្នឹងហើយជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ រីឯអ្នករាល់គ្នាជាមែក**" ហើយព្រះយេស៊ូបានបញ្ជាក់ជាច្រើនដងនៅក្នុងអត្ថបទថ្ងៃនេះថា "**ប្រសិនបើយើងស្ថិតនៅជាប់ព្រះអង្គ ហើយព្រះបន្ទូលរបស់ព្រះអង្គស្ថិតនៅក្នុងយើង នោះយើងអាចបង្កើតផល ហើយផលដ៏បរិបូណ៌**"។ ក្នុងអត្ថបទគម្ពីរដំណឹងល្អ នៅថ្ងៃនេះនាំឲ្យយើងរិះគិតពិចារណា៖

**ទីមួយ** នាំឲ្យយើងនឹកឃើញដល់ព្រះបិតាដែលជាម្ចាស់ចម្ការ ព្រះអង្គមានព្រះហឫទ័យស្រឡាញ់យើង ព្រះអង្គជាម្ចាស់ចម្ការដែលបានរៀបចំដីយ៉ាងល្អស្អាត ដែលបានដាំដើមទំពាំងបាយជូរ និងដែលបានរៀបចំរបងការពារយ៉ាងមាំ។ នៅក្នុងគម្ពីររបស់សាសនាយូដា គេធ្លាប់ប្រៀបធៀបប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទៅនឹងចម្ការទំពាំងបាយជូរ។ ដូច្នេះ ប្រជារាស្ត្រអ៊ីស្រាអែលជាចម្ការទំពាំងបាយជូរដែលព្រះជាម្ចាស់បានរៀបចំ ព្រះអង្គបានជ្រើសរើសមានបុព្វបុរសបន្ទាប់មកមានព្យាការីផ្សេងៗដែលនាំគេឲ្យស្គាល់ព្រះជាម្ចាស់ រៀបចំគម្រោងការដើម្បីសង្គ្រោះមនុស្សលោក។ ក្រោយមកយើងដឹងថា ចុងក្រោយបំផុតព្រះបិតាព្រះអង្គបានចាត់ព្រះបុត្រាដែលជាព្រះយេស៊ូឲ្យយាងមកក្នុងលោកនេះ។ តាមរយៈព្រះយេស៊ូ ព្រះអង្គបានជ្រើសរើសយើងទាំងអស់គ្នាទៅជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់។ ប្រសិនបើ ជីវិតរបស់យើងជាប់ជាមួយនឹងព្រះយេស៊ូតាមរយៈអគ្គសញ្ញាជ្រមុជទឹកដែលយើងទទួល យើងអាចបង្កើតផលផ្លែ។ ព្រះបិតា

ដែលបានរៀបចំអ្វីៗទាំងអស់នេះ គឺសម្រាប់មនុស្សលោកទាំងឡាយ និងជាពិសេសសម្រាប់ឲ្យយើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ ស្ថិតជាប់ជាមួយនឹងព្រះអង្គដើម្បីបង្កើតផលផ្លែ។

**ទីពីរ** តាមរយៈព្រះយេស៊ូដែលព្រះអង្គបានជ្រើសរើសយើង យើងទៅជាប្រជារាស្ត្រថ្មីរបស់ព្រះជាម្ចាស់។ ឲ្យយើងគិតពិចារណា **តើយើងត្រូវធ្វើដូចម្តេច ដើម្បីឲ្យជីវិតរបស់យើងជាប់ជាមួយព្រះអង្គដែលជាដើមទំពាំងបាយជូរដ៏ពិតប្រាកដ?** យើងដឹងថា ពេលដែលយើងរស់នៅក្នុងសម័យដែលមានកូវីដ១៩ យើងអត់មានឱកាសដើម្បីជួបជុំគ្នាទេ ប៉ុន្តែព្រះសហគមន៍បានទូន្មាន និងព្យាយាមឲ្យយើងទាំងអស់គ្នាអាចចូលរួមអភិបូជាពីចម្ងាយបាន ដោយចិត្តគំនិតរបស់យើង ដោយវិញ្ញាណរបស់យើងដែលចូលរួមក្នុងម៉ោងជាមួយគ្នា ដែលព្រះសហគមន៍ផ្សាយតាមរយៈបណ្តាញឌីជីថលសព្វថ្ងៃនេះ។ ពេលណាយើងចូលរួមដោយយកចិត្តទុកដាក់ ក្នុងម៉ោងជាមួយគ្នា យើងបានទទួលដែរ ហើយនេះជាអភិបូជាដែលផ្តល់ឲ្យយើងស្ថិតនៅជាប់ជាមួយព្រះជាម្ចាស់។ កាលពីម្សិលមិញ លោកអភិបាលទាំងបីមានប្រជុំនៅមណ្ឌលសកម្មភាពភ្នំពេញថ្មី លោកអភិបាលបានរំឭកថា សព្វថ្ងៃយើងគួររកមធ្យោបាយដើម្បីឲ្យបងប្អូនគ្រីស្តបរិស័ទយើងបានទទួលព្រះកាយដោយផ្ទាល់ មិនគ្រាន់តែទទួលតាមផ្លូវវិញ្ញាណ ប៉ុន្តែអាចទទួលព្រះកាយផ្ទាល់។ មានន័យថា ប្រហែលជាយើងអាចចែកជាក្រុមតូចៗ ដើម្បីចូលរួមអភិបូជា ប៉ុន្តែយើងគោរពតាមច្បាប់របស់រាជរដ្ឋាភិបាល ដោយយើងមានគ្នាមិនលើសពី១០នាក់ និងចែកតាមថ្ងៃផ្សេងៗគ្នា។ ដ្បិតព្រះកាយព្រះគ្រីស្តដែលយើងទទួលតាមរយៈអគ្គសញ្ញអរព្រះគុណ ជាអាហារម្យ៉ាងដែលនាំឲ្យយើងមានជីវិតជាប់ជាមួយព្រះយេស៊ូដែលជាដើមទំពាំងបាយជូរ ដើម្បីឲ្យយើងបង្កើតផលផ្លែបានច្រើន។

**ទីបី** ខ្ញុំចង់ឲ្យយើងចាប់អារម្មណ៍គឺ ពេលណាដែលយើងនិយាយអំពីជាប់ជាមួយដើម យើងនិយាយអំពីការរួបរួមគ្នារបស់ព្រះសហគមន៍ ការឯកភាពជាអង្គតែមួយរបស់យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទដែលមានសម្តេចប៉ាប មានលោកអភិបាល លោកបូជាចារ្យ ព្រមទាំងអស់អ្នកដែលមានមុខងារសំខាន់ៗក្នុងព្រះសហគមន៍ និងគ្រីស្តបរិស័ទយើងទាំងអស់។ ដោយសារតែព្រះសហគមន៍យើងមានរចនាសម្ព័ន្ធយ៉ាងច្បាស់លាស់ ទើបនាំឲ្យយើងមានការរួបរួមគ្នាជាអង្គតែមួយជាមួយនឹងព្រះគ្រីស្ត។ យើងជាប់ជាមួយគ្នាថែមទៀត ដោយនឹកឃើញដល់បុព្វបុរសនៃជំនឿរបស់យើង នៅប្រទេសកម្ពុជាយើងនៅទីនេះជាទឹកដីមរណសាក្សី ដែលយើងនឹកឃើញដល់លោកអភិបាលឆ្នារ សាឡាស់ លោកឆ្នារ សាឡឹម លោកត្រឿង សម្រើន ដែលជាប់នឹងប្រវត្តិសាស្ត្រនៅកម្ពុជា ជាប់ប្រវត្តិសាស្ត្រព្រះសហគមន៍សាកល មានឫស។ នៅពេលណាយើងនឹកឃើញដល់សេចក្តីនេះ មានន័យថាយើងរួមគ្នាជាព្រះសហគមន៍ដែលជាប់នឹងប្រវត្តិនៃព្រះសហ

គមន៍ បើយើងរួមគ្នារបៀបនេះ យើងអាចបង្កើតផលផ្លែបានច្រើន។ ដូច្នេះ ដើម្បីឲ្យយើងបង្កើតផលផ្លែឲ្យបានច្រើន ឲ្យយើងមើលគំរូរបស់យើង។ នៅថ្ងៃនេះយើងធ្វើបុណ្យព្រះនាងម៉ារី ប៉ុន្តែខ្ញុំចង់ឲ្យយើងចាប់អារម្មណ៍ពីគំរូរបស់យើងជាមរណសាក្សីនៅប្រទេសកម្ពុជាដែរ។ ទោះបីសម័យខ្មែរក្រហមគេរស់នៅក្នុងកាលៈទេសៈពិបាក នៅក្នុងហោប៉ៅរបស់លោកអភិបាល ឆ្មារ សាឡាស់ គេរកឃើញមានគម្ពីរជាភាសាបារាំងតូចមួយ លោកព្យាយាមអានអត្ថបទព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនេះជាគំរូមួយសម្រាប់យើង។ អស់លោកអាចចាកចេញពីប្រទេសកម្ពុជាបាន ប៉ុន្តែអស់លោកបានសុខចិត្តរស់នៅក្នុងប្រទេសកម្ពុជាដោយជំនឿ ដើម្បីរស់នៅរួមស្លាប់ជាមួយហ្វូងចៀមរបស់ព្រះជាម្ចាស់នៅទីនេះ។ អស់លោកបានបូជាជីវិត អស់លោកបានព្យាយាមស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងព្យាយាមថ្វាយអភិបូជានៅលើគ្រែនេះ ដែលជាទីសម្គាល់និងជាសាក្សីស្រាប់សម្រាប់យើង ដើម្បីបន្តជំនឿរហូតដល់យើងសព្វថ្ងៃ និងជួយពង្រឹងជំនឿរបស់យើង។ ខ្ញុំគិតថា នេះជាគំរូមួយដ៏ពិសេសដើម្បីឲ្យយើងនឹកឃើញ ដើម្បីឲ្យយើងជាគ្រីស្តបរិស័ទនៅប្រទេសកម្ពុជាដែលមានការលំបាក ឲ្យយើងទាំងអស់គ្នាព្យាយាមតទៅមុខទៀត។ យើងចូលរួមអធិដ្ឋាន ព្យាយាមស្តាប់ព្រះបន្ទូល ចូលរួមអភិបូជាពិចម្ងាយ ដើម្បីឲ្យជីវិតរបស់យើងបានជាប់ជាមួយព្រះអង្គ ដើម្បីឲ្យយើងបង្កើតផលផ្លែ។

**ទីបួន** យើងដឹងថា នៅពេលដែលយើងបាត់អ្វីៗទាំងអស់នៅសម័យខ្មែរក្រហម យើងមានឈើឆ្កាងរបស់លោកអភិបាលមួយដែលជាប់ថែរក្សាទុកនៅក្នុងសម្បុកមាន់។ ដែលឈើឆ្កាងនេះនៅបន្តពីលោកអភិបាល អ៊ីវ រ៉ាម៉ូស ទៅលោកអភិបាល ឆ្មារ សាឡាស់ ពីលោកអភិបាល ឆ្មារ សាឡាស់ បន្តទៅលោកអភិបាល អ៊ីវ រ៉ាមូស បន្តពីលោកអភិបាល អ៊ីវ រ៉ាម៉ូស ទៅលោកអភិបាល អេមីល ពីលោកអភិបាល អេមីល ឥលូវបន្តដល់លោកអភិបាល អូលីវីយេ។ នេះជាអ្វីមួយ ដែលជាប់នឹងប្រវត្តិសាស្រ្តរបស់យើង ដែលបង្ហាញពីការឯកភាពរបស់ព្រះសហគមន៍យើង នេះជាគំរូមួយពិសេសសម្រាប់យើងទាំងអស់គ្នាជាគ្រីស្តបរិស័ទ។ ទោះបីយើងជួបការលំបាក តែសូមយើងព្យាយាមតទៅមុខទៀត យើងមិនអស់សង្ឃឹម ត្បិតបើយើងជាប់ជាមួយព្រះសហគមន៍ ជាប់ជាមួយអ្នកដឹកនាំព្រះសហគមន៍ យើងសង្ឃឹមថាយើងនឹងអាចបង្កើតផលផ្លែ។ ផលផ្លែដ៏ប្រសើរជាងគេរបស់យើង គឺការអធិដ្ឋាន ការសម្តែងព្រះទ័យមេត្តាករុណារបស់ព្រះជាម្ចាស់ដល់បងប្អូនដែលយើងជួបសព្វថ្ងៃនេះ ជាពិសេសក្នុងកាលៈទេសៈពិសេសជាពេលវេលាមួយល្អ សម្រាប់យើងចែកសេចក្តីស្រឡាញ់ដល់បងប្អូន ដើម្បីឲ្យផលដែលយើងបង្កើតទៅជាផលដ៏បរិបូណ៌ ជាផលដែលនៅស្ថិតស្ថេរសម្រាប់ឲ្យមនុស្សលោកលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់។

សូមព្រះអង្គប្រទានពរដល់យើងទាំងអស់គ្នា ប្រទានពរដល់ព្រះសហគមន៍គ្រប់ទីកន្លែង ជាពិសេសនៅប្រទេសកម្ពុជា នៅភូមិភាគភ្នំពេញ ឲ្យយើងបានបង្កើតផលតាមរយៈដើមទំពាំងបាយជូរតែមួយគត់គឺព្រះគ្រីស្ត ឲ្យផលរបស់យើងបាននៅស្ថិតស្ថេរ និងផ្តល់ការសង្គ្រោះដល់មនុស្សលោក។ អាម៉ែន៕